ក

# មាតិកា

## I~ ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៣ ស្តីពីការតែងតាំងលោក **តែ ហាំង** ជា **ឧកញ៉ា** ១៨៥៨

១១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៤ ស្តីពីការតែងតាំងលោកស្រី **ម៉ុ នារី** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ១៨៥៩

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៨ ស្តីពីការតែងតាំង :

១- លោក **តូច មុនីសាគរ** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភាមានឋានៈស្មើ **រដ្ឋលេខាធិការ**

២- លោក **ទ៉ាន់ ធី** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ១៨៦០

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១២៩ ស្តីពីការតែងតាំងលោក **អ៊ុយ មុនីរ៉ា** និងលោក **ប្រាក់ គឹមថុន** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ១៨៦១

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣០ ស្តីពីការតែងតាំងលោក **ខេត ប៊ុនតុង** និងលោក **ប៊ិនហេង សូរស្មី** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មាន ឋានៈស្មើ **អនុរដ្ឋលេខាធិការ** ១៨៦២

១២-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣១ ស្តីពីការតែងតាំងលោក **ឈួន សយ** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ១៨៦៣

១៨-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤០ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុង ផល្លា** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារវិនិយោគ និងពាណិជ្ជកម្ម មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ១៨៦៤

១៨-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤១ ស្តីពីការតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ១៨៦៥

១៨-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤២ ស្តីពីការសំរួលភារកិច្ចឯកឧត្តម **រុខ ផ្កាមកែសន** ពីសមាជិកព្រឹទ្ធសភា និងតែងតាំង ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋមន្ត្រី** ១៨៦៦

១៨-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៣ ស្តីពីការតែងតាំង ឯកឧត្តម **ជា សុន** ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួសឯកឧត្តម **រុខ ផ្កាមកែសន** ដែលបានសុំលាលែង ១៨៦៧

១៨-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៤ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម **ឡៃម សារិន** ទីប្រឹក្សាសម្តេច**ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ១៨៦៨

២១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៧ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោកស្រី **ខារ៉ូល បែលឡាមី** ( Ms. **Carol Bellamy** ) នូវ **គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា** ១៨៦៩

២១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៩ ស្តីពីការកំណត់ប្រភេទសត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូប នៃព្រះរាជាណាចក្រកម្ពុជា ១៨៧០

២៣-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៥១ ស្តីពីការផ្ទេរក្របខ័ណ្ឌ ឧត្តមសេនីយ៍ទោ **ចាន់ ចាសនា** ពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃក្រសួងមហាផ្ទៃ មកបំរើការងារក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ ១៨៧៨

២៣-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៥២ ស្តីពីការតែងតាំងមន្ត្រីរាជការ នៃក្រសួងសុខាភិបាល ចំនួន ០២ រូប ១៨៧៩


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៤-៣-២០០៥ -អនុក្រឹត្យ លេខ ៤៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៨៨០

២៥-៣-២០០៥ -អនុក្រឹត្យ លេខ ៤៩ អនក្រ.បក ស្តីពីទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ ឧសភា ១៨៨២

២៥-៣-២០០៥ -អនុក្រឹត្យលេខ៥០ អនក្រ.បក ស្តីពីការបង្កើតតំបន់ឧស្សាហកម្ម (ខេមបូឌា) ហ្វ្រី ត្រេដ ហ្សូន ឌីវើឡុបមែន ខបផូរ៉េស៊ីន(CAMBODIA)Free Trade Zone Development Corporation ១៨៨៥

៣១-៣-២០០៥ -អនុក្រឹត្យ លេខ ៥១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៨៨៧

២៤-៣-២០០៥ -អនុក្រឹត្យ លេខ ៣១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៨៩

| | | |
|---|---|---|
| ២៥-៣-២០០៥ | -អនុក្រឹត្យ លេខ ៣១៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៨៩០ |
| ២៥-៣-២០០៥ | -អនុក្រឹត្យ លេខ ៣១៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៨៩១ |
| ២៥-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២០ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៨៩២ |
| ២៥-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២១ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៨៩៤ |
| ២៨-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២២ អនក្រ.តត ស្តីពីការបំពេញបន្ថែមសមាសភាពក្រុមប្រឹក្សាកំណែទំរង់កងយោធពលខេមរភូមិន្ទ | ១៩០៤ |
| ២៨-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៣ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ | ១៩០៦ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៩០៨ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៥ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ១៩៦៣ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៦៥ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ១៩៦៦ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ១៩៦៧ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៩៦៨ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣៣០ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៩៦៩ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣៣១ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៩៧០ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣៣២ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៩៧១ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣៣៣ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៩៧២ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣៣៤ អនក្រ.តត ស្តីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិវរមន្ត្រី ជូនមន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៩៧៣ |
| ២៩-៣-២០០៥ | -អនុក្រឹត្យ លេខ ៣៣៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៩៨៣ |

២៩-៣-២០០៥ -អនុក្រឹត្យ លេខ ៣៣៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៩៨៤
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៣៧ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល អគ្គនាយក និង មន្ត្រីត្រួតពិនិត្យ នៃក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ១៩៨៥
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៣៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៩៨៧
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៣៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ១៩៩៤
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៩៩៦
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៩៩៧
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៩៩៨
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៩៩៩
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០០១
៣០-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤៥ អនក្រ.តត ស្តីពីការអនុវត្តវិន័យនាយនគរបាលជាតិ ២០០៣
៣១-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២០០៥
៣១-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤៧ អនក្រ.តត ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២០០៦
៣១-៣-២០០៥ -អនុក្រឹត្យ លេខ ៣៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០០៨

## III~ការខារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២២-៣-២០០៥ -ប្រកាសលេខ ១៨១ សហវ.ប្រក ស្តីពីការអនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ និង រដ្ឋបាលសំរាប់កម្មវិធីសិលា ២០១០
២៨-៣-២០០៥ -ប្រកាសលេខ ១៨៦ សហវ.ប្រក ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងការបង្វិលសងអាករលើតម្លៃបន្ថែម (VAT) ជូនអង្គការ និងបណ្តាក្រុមហ៊ុន ២០១២
៣០-៣-២០០៥ -ប្រកាសលេខ ១៨៧ សហវ.ប្រក ស្តីពីអាណត្តិ និងការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមសហគ្រាសសាធារណៈ ២០១៤

### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៦-៣-២០០៥ -លិខិតលេខ ៦១១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ផល ពេលា លោហៈ អ៊ឹមផត អិចផត** ២០១៦

១៨-៣-២០០៥ -លិខិតលេខ ៦២២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីធី & ជី** ២០១៨

១៨-៣-២០០៥ -លិខិតលេខ ៦២៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឃុន សំបូរផល ពាណិជ្ជ អ៊ឹមផត អិចផត** ២០២០

១៨-៣-២០០៥ -លិខិតលេខ ៦២៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៊ី អេស ប៊ី ខសមេធិក (ខេមបូឌា)** ២០២២

១៨-៣-២០០៥ -លិខិតលេខ ៦២៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេម អឌូ ផាត & សឺវីស** ២០២៤

១៨-៣-២០០៥ -លិខិតលេខ ៦២៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៊ី ធំបុល ប៊ូរ៉** ២០២៦

២១-៣-២០០៥ -លិខិតលេខ ៦៣០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆាយអមីរ៉ន អ៊ិន** ២០២៨

២១-៣-២០០៥ -លិខិតលេខ ៦៣២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អូអេសអិម គ្រុប** ២០៣០

២១-៣-២០០៥ -លិខិតលេខ ៦៣៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សិន តៃ ឃ្លាមេន (ខេមបូឌា)** ២០៣២

២២-៣-២០០៥ -លិខិតលេខ ៦៤៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស ឌី អិល (ខេមបូឌា) គ្រេឌិង អ៊ឹមផត & អិចផត** ២០៣៤

២២-៣-២០០៥ -លិខិតលេខ ៦៤៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ី.អេស.តី អិចប្រេស សឺវិស** ២០៣៦

២២-៣-២០០៥ -លិខិតលេខ ៦៥០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អាស៊ាន ទូត អ៊ិនដាស្ត្រី** ២០៣៨

២២-៣-២០០៥ -លិខិតលេខ ៦៥៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម្រេត ឃែរ (ខេមបូឌា)** ២០៣៩

២២-៣-២០០៥ -លិខិតលេខ ៦៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សៀង យ៉ុង ឃីង គ្រុប** ២០៤១

២២-៣-២០០៥ -លិខិតលេខ ៦៥៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គ្លីប អេទើប្រ៊ន** ២០៤៣

២៣-៣-២០០៥ -លិខិតលេខ ៦៦៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខូនិចល ម៉ៃអឺត សូហ្វវែរ (ខេមបូឌា)** ២០៤៥

២៣-៣-២០០៥ -លិខិតលេខ ៦៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **វ៉ៃ យុន ហេង** ២០៤៧

២៤-៣-២០០៥ -លិខិតលេខ ៦៧៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ចតុមុខ អ៊ិនធើណេសិនណល អ៊ីមផត អិចផត** ២០៤៩

២៤-៣-២០០៥ -លិខិតលេខ ៦៧៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ូ ហ្វ៊ូ អ៊ីមផត អិចផត** ២០៥១

## ៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

៣០-៣-២០០៥ -ប្រកាសលេខ ៤៤៥ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ពណ្ណរាយ ស្ថិតនៅក្នុងឃុំចើងដើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ២០៥៣

៣០-៣-២០០៥ -ប្រកាសលេខ ៤៤៦ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ បឹង ស្ថិតនៅក្នុងឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ២០៥៤

៣០-៣-២០០៥ -ប្រកាសលេខ ៤៤៧ អយក.ប្រក ស្តីពីការ បើកអនុវិទ្យាល័យ ប្រាសាទ ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ ២០៥៥

៣០-៣-២០០៥ -ប្រកាសលេខ ៤៤៨ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ បឹងល្វា ស្ថិតនៅក្នុងឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ២០៥៦

៣០-៣-២០០៥ -ប្រកាសលេខ ៤៤៩ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ឧទុម្ពរ ស្ថិតនៅក្នុងឃុំស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ២០៥៧

៣០-៣-២០០៥ -ប្រកាសលេខ ៤៥០ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ កកោះ ស្ថិតនៅក្នុងឃុំកកោះ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ២០៥៨

៣០-៣-២០០៥ -ប្រកាសលេខ ៤៥១ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ កួនភ្នំ ៣២ ស្ថិតនៅក្នុងឃុំតាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង ២០៥៩

៣០-៣-២០០៥ -ប្រកាសលេខ ៤៥២ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ អំពិលប្រាំដើម ស្ថិតនៅក្នុងឃុំអំពិលប្រាំដើម ស្រុកបវេល ខេត្តបាត់ដំបង ២០៦០

៣០-៣-២០០៥ -ប្រកាសលេខ ៤៥៣ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ចម្លងគួយ ស្ថិតនៅក្នុងឃុំអូរសិរល ស្រុកសំឡូត ខេត្តបាត់ដំបង ២០៦១

៣០-៣-២០០៥ -ប្រកាសលេខ ៤៥៤ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ កូនភ្នំមិត្តភាព ស្ថិតនៅក្នុងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ២០៦២

៣០-៣-២០០៥ -ប្រកាសលេខ ៤៥៥ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ បាយដំរាំ ស្ថិតនៅក្នុងឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង ២០៦៣

៣០-៣-២០០៥ -ប្រកាសលេខ ៤៥៦ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ តាហែន ស្ថិតនៅក្នុងឃុំក្តុលតាហែន ស្រុកបវេល ខេត្តបាត់ដំបង ២០៦៤

នស/រកត/០៣០៥/១២៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

**តែងតាំង**

លោក តែ ហាំង

ជា

**ឧកញ៉ា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៣.១២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

B 92

3/3

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកស្រី **ម៉ី ណារី** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា និតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤.០៥០៣.១២៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥*

លេខ ១៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ. ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/ ១២៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង :

១- លោក **គួច មុនីសាគរ** ជាទីប្រឹក្សា សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- លោក **ម៉ាំង ធី** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣រស.០៥០៣.១៣១*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៥*

លេខ ១៣០ ច.ល
**ដើម្បីចម្លងចេញ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១២៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង :

១- លោក អ៊ុយ មុនីរ៉ា ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- លោក ប្រាត់ គឹមថុន ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស.០៥០៣.១៣៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៥*

លេខ ១១១ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សោ ខឹម តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាន្ធូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង :

១- លោក **ធេង ប៊ុនគួច** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

២- លោក **មិនហេង សួរស្ទី** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.០៥០៣.១៣៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៥*

លេខ ១៣២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៣១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោក **ឈួន សយ** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ ។**

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៣.១៣៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៥*

លេខ: ១៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **អ៊ឹង ផល្លារ** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារវិនិយោគ និងពាណិជ្ជកម្ម មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

៣៤.០៥០៣.១៤៦

**ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៥**

លេខ ១០៧៤ ច.ល
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
... តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតម្លើងឋានន្តរស័ក្តិ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោម :

**ក-ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ :**

១- លោកឧត្តមសេនីយ៍ត្រី **អៅ គឹមឈួន** អត្តលេខ ០០៧៤

២- លោកឧត្តមសេនីយ៍ត្រី **ហេង ចាន់ថា** អត្តលេខ ០៤១៤ ។

**ខ-ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី :**

១- លោកវរសេនីយ៍ឯក **យន់ សន** អត្តលេខ ០២៦២

២- លោកវរសេនីយ៍ឯក **ជុក គឹមហួរ** អត្តលេខ ០៣៩០

៣- លោកវរសេនីយ៍ឯក **ម៉ាង វិសុី** អត្តលេខ ០៧៧០ ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣ស.០៥០៣.១៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៥

លេខ ៦២៥ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សៅ ឌាន់

២/២

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១ :** សំរួលភារកិច្ចឯកឧត្តម **រួច ផ្លាមកែសន** ពីសមាជិកព្រឹទ្ធសភា ។

**មាត្រា ២ :** តែងតាំងឯកឧត្តម **រួច ផ្លាមកែសន** ជាទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើរដ្ឋមន្ត្រី ។

**មាត្រា ៣ :** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

*ពរល.០៥០៣.១៤៨*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៥*

[illegible] ថ.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ [illegible] ឆ្នាំ២០០៥

**[illegible]រាជរដ្ឋាភិបាល**

**[illegible]**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៥ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សំណើរបស់គណបក្សប្រជាជនកម្ពុជា ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០០៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៥ ខែមិនា ឆ្នាំ ២០០៥

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ជា សួន** ជាសមាជិក ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួសឯកឧត្តម **រួខ ផ្លាមតែសន** ដែលបានសុំលាលែង ។

**មាត្រា ២:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧-០៥០៣-១៤៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៥*

លេខ: ១៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ០៣ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបុរេណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត លេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតម្លើងឋានៈជូន ឯកឧត្តម ញ៉ែម សារ៉ន ទីប្រឹក្សាសម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.០៥០៣.១៥០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៥

លេខ ១៤៧៩ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ខាន់

នស/រកត/០៣០៥/១៤៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

## ប្រោសព្រះរាជទាន

ចំពោះ

លោកស្រី **ខារ៉ូល បែលឡាមី**
(Ms. **Carol Bellamy**)

នូវ

**គ្រឿងឥស្សរិយយស សហមេត្រី**
**ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស·០៥០៣·១៥៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥*

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
[illegible]
ណាម៍ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤៩

## ស្តីពី

## ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូប នៃព្រះរាជាណាចក្រកម្ពុជា

☆☆☆☆☆

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

## ប្រកាសបង្គាប់

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងកំណត់ឈ្មោះសត្វ និង រុក្ខជាតិ ដែលមានអត្តិភាព និង សារប្រយោជន៍ពិសេស សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញនូវមរតកធម្មជាតិដ៏មានតម្លៃ និង លើកតម្កើងនូវមោទនភាពជាតិ ។

**មាត្រា ២.-**

សត្វ និង រុក្ខជាតិ សម្រាប់ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា មានឈ្មោះទៅតាមប្រភេទដូចខាងក្រោម :

| | | |
|---|---|---|
| ១- ប្រភេទសត្វចតុប្បាទ | : | សត្វគោព្រៃ |
| ២- ប្រភេទបក្សី | : | សត្វត្រយ៉ង |
| ៣- ប្រភេទឧរង្គសត្វ | : | អណ្តើកសរសៃ (អណ្តើកហ្លួង) |
| ៤- ប្រភេទមច្ឆា | : | ត្រីគល់រាំង |
| ៥- ប្រភេទរុក្ខជាតិ | : | ដើមត្នោត |
| ៦- ប្រភេទផ្កា | : | ផ្ការំដួល |
| ៧- ប្រភេទផ្លែឈើ | : | ផ្លែចេកពងមាន់ |

រូបភាព និង លក្ខណៈវិនិច្ឆ័យនៃសត្វ និង រុក្ខជាតិនីមួយៗ ដូចចែងខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ទី២ ទី៣ ទី៤ ទី៥ និង ទី៦ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

សត្វ និង រុក្ខជាតិ ដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវមានវិធានការថែរក្សាការពារ អភិរក្សឱ្យមាននិរន្តរភាព និង ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ។

**មាត្រា ៤.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

៣៣៧.០៥០៣.០៥៥

លេខ ១២៤.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ ឆាន់

3/9

# ឧបសម្ព័ន្ធ ទី១

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/២៤៩ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥
## ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ១- គោព្រៃ (*Bos sauveli*) ជាសត្វនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះ **គោព្រៃ** ជាន័យដើម និង ន័យត្រង់នៃភាសាជាតិខ្មែរតែម្តង ហើយត្រូវបានសត្វវិទូអន្តរជាតិទទួលស្គាល់ និង ដាក់នាមដូចៗគ្នា ទោះជាភាសាអង់គ្លេស អេស្ប៉ាញ និង បារាំង គឺប្រើពាក្យតែមួយ "**Kouprey**"។ វាមានឈ្មោះវិទ្យាសាស្ត្រ " *Bos sauveli* " មានប្រវែងដងខ្លួនពី ២.១-២.៣ ម៉ែត្រ មានកម្ពស់ពី ១.៧-១.៩ ម៉ែត្រ និង ទម្ងន់ពី ៧០០-៩០០ គីឡូក្រាម។ គោព្រៃមានរូបរាងស្រដៀងនឹងទន្សោង មានប៉ូរវែងធ្លាក់ចុះដល់ជង្គង់ និង ហៀរស្ទើរតែដល់ដីចំពោះគោឈ្មោល ។ ស្នែងគោព្រៃឈ្មោល និង ញី មានលក្ខណៈប្លែកគ្នា ដោយស្នែងឈ្មោលធំជាង ដុះចេញកោងទៅមុខ និង ងើបឡើងលើ ព្រមទាំងមានព្រុយចុងស្នែង។ ស្នែងញីដុះមកខាងមុខរាងងើបបន្តិច ហើយគួចរមួលឡើងលើ។ ចាប់ពីជើងក្រោមជង្គង់ចុះមក មានពណ៌ស ឬ ប្រផេះ និង ប្រផេះចាស់នៅពេលមានអាយុច្រើន ។ កាលពីសម័យមុនសង្គ្រាម គោព្រៃត្រូវហាមបរបាញ់តាមរយៈប្រកាសលេខ ១៩១ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៦០។ ក្រោយរបប **ប៉ុល ពត** គោព្រៃក៏ត្រូវហាមបរបាញ់ម្តងទៀតតាមរយៈប្រកាសលេខ ៣៥៩ កសក.ប្រក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ គោព្រៃត្រូវហាមឃាត់មិនឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយបានចុះក្នុងបញ្ជីឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES និង អនុសញ្ញា Convention on Migratory Species ។ ពិភពលោកបានចាត់ទុកគោព្រៃជាប្រភេទសត្វ **ជិតផុតពូជបំផុត** (Critical Endangered) ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN។ ក្នុងទសវត្សឆ្នាំ ៦០ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ និង ប្រកាសថា: គោព្រៃជានិមិត្តរូបនៃមរតកធម្មជាតិកម្ពុជា។ គោព្រៃក៏ត្រូវចរិកទុកនៅក្នុងបទចំរៀងប្រជាប្រិយរបស់ខ្មែរតាំងពីយូរយារណាស់មកហើយ ជាពិសេសបទចំរៀងដែលមានលក្ខណៈរៀបរាប់អំពីធម្មជាតិ ប្រដូចភាពសុខសាន្តនៃការរស់នៅរវាងមនុស្ស សត្វ និង ធម្មជាតិ គឺតែមួយ ។ គោព្រៃជាថនិកសត្វស្លូតរស់នៅជាហ្វូងៗ អាចឃើញមានទៅលាយជាមួយហ្វូងទន្សោង ខ្ទីង ឬ ប្រើស។ ជាសត្វវៀងវៃ រហ័សរហួន ឆាប់ភ្ញាក់ផ្អើលជាងប្រភេទសត្វក្នុងត្រកូលគោសាមិដដូចគ្នា ពូកែស្រង់ក្លិន និង គេចវេសចេញពីមនុស្ស ។ មានកម្លាំងខ្លាំង ពូកែធន់នឹងកំដៅថ្ងៃ អត់ធន់នឹងចំណីអាហារដែលមានគុណភាពទាប និង ធន់នឹងជំងឺគោឆ្លង។



៤/៩
~~~~~

# ឧបសម្ព័ន្ធ ទី២

## នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/១៤៩ចុះថ្ងៃទី...៣១... ខែ...មីនា... ឆ្នាំ ២០០៥ ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ២- ត្រយ៉ង (*Pseudibis gigantea*) ជាបក្សីនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "ត្រយ៉ង ឬ ក្ងួយក្ស ឬ ឪលើក" ។ វាមានឈ្មោះវិទ្យាសាស្ត្រ "***Pseudibis gigantea***" និង ជាភាសាអង់គ្លេស គឺ "**Giant Ibis**"។ វាមានពណ៌សម្បុរប្រផេះក្រម៉ៅ ជើងពណ៌ក្រហមព្រាលៃត ជំពុះរាងកោងខុបចុះ និង ប្រវែងដងខ្លួន ១០៤ ស.ម ។ ប្រភេទនេះត្រូវការពារដោយប្រកាសលេខ ៣៥៩ កសក.ប្រក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ពិភពលោកក៏បានចាត់ទុកត្រយ៉ងជាប្រភេទ **ជិតផុតពូជបំផុត (Critical Endangered)** ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN ដូចគ្នានឹងគោព្រៃដែរ។ ត្រយ៉ងជាប្រភេទសត្វស្លាបដែលកាលពីដើមឡើយមានរាយប៉ាយទូទាំងតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែបច្ចុប្បន្ននេះ មាននៅតែក្នុងភូមិភាគខាងជើង និង ឦសាន្តនៃប្រទេសកម្ពុជាប៉ុណ្ណោះ ។ សត្វត្រយ៉ងមានចារឹកក្នុងបទចំរៀងប្រជាប្រិយ និង រឿងនិទានបុរាណខ្មែរ ។ ប្រជារាស្ត្រមានជំនឿថា: ជាសត្វមានភាពវាងវៃ កាលបើមានការបរបាញ់ពុំបានសម្រេចនៅកន្លែងណាមួយហើយ វានឹងមិនត្រឡប់មកទីនោះវិញជាលើកទី២ ឡើយ។ គេមានជំនឿប្រើប្រាស់ឈាមរបស់វាសម្រាប់ព្យាបាលជំងឺគ្រុនចាញ់នៅតាមតំបន់ដាច់ស្រយាល។ ជាប្រភេទសត្វមានប្រជាប្រិយភាព ប្រជាជនមាននិស្ស័យស្រឡាញ់ចូលចិត្តជាពិសេសសម្រែកទាបភ្លឺរបស់វា ដែលជិតជាប់ក្នុងក្រអៅបេះដូងរបស់ប្រជាកសិករខ្មែរក្នុងអត្ថន័យនៃការឆ្លើយឆ្លងសេចក្តីស្នេហាក៏ដូចជាការរំលឹកពេលវេលាត្រូវចាកចេញទៅធ្វើស្រែចំការផងដែរ ។ ចំណីរបស់វាគឺ សត្វឥតឆ្អឹងកងដែលរស់នៅក្នុងភក់ ដូចជា: ខ្យង ជន្លេន ក្តាម ។ល។ វាចូលចិត្តរស់នៅក្នុងព្រៃរបោះស្ងួតមានតំបន់ដីសើមច្រើន (ត្រពាំង បឹង ទន្លេ) ។ វាមានដំណើរយឺតៗរកចំណីលើដី និង ទំលើដើមឈើ ដើម្បីសម្រាក និង គេចពួនពីសត្រូវ។ ជាប្រភេទសត្វទើបតែរកឃើញជាថ្មីឡើងវិញនៅកម្ពុជាបន្ទាប់ពីពិភពលោកបានអះអាងថាផុតពូជហើយនោះ ។ ចំនួនរកឃើញថ្មីៗ នៅខេត្តព្រះវិហារ គឺមិនតិចជាង ១០០ ក្បាលឡើយ ដែលជារបាយមួយច្រើនជាងគេក្នុងពិភពលោក។ ប្រទេសកម្ពុជា ជាប្រទេសទីមួយ ដែលបានផ្តល់រូបថតនៃប្រភេទត្រយ៉ងនេះក្នុងធម្មជាតិមុនគេលើពិភពលោក។ ឥឡូវរូបភាពសត្វនេះត្រូវផ្សព្វផ្សាយទូទាំងពិភពលោកដោយទស្សនាវដ្តី National Geographic Magazine នៃសហរដ្ឋអាមេរិក។ យើងបានចេញអនុក្រឹត្យបង្កើតតំបន់ព្រៃអភិរក្សធនធានសេនេទិច និង សត្វព្រៃ "ខេត្តព្រះវិហារ" ក៏ជាមូលហេតុនៃការអភិរក្សសត្វត្រយ៉ងនេះជាចម្បងដែរ ។ វាជាប្រភេទសត្វជិតផុតពូជបំផុត ដែលអង្គការអភិរក្សពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលនានាកំពុងមានចំណាប់អារម្មណ៍ជួយផ្តល់ជំនួយការពារថែរក្សាប្រភេទសត្វនេះឱ្យខាងតែបាន ម្យ៉ាងទៀតដោយវាមានសោភ័ណភាព និង រូបរាងស្រស់ស្អាត ជាពិសេសទើបតែរកឃើញឡើងវិញថ្មីៗនេះផងនោះ វាជាប្រភពទាក់ទាញទេសចរណ៍ដ៏សំខាន់មួយ ។



៩/៧
✓
~~~~~

# ឧបសម្ព័ន្ធ ទី៣

## នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៥/២៤៩ ចុះថ្ងៃទី...២១... ខែ..មីនា.... ឆ្នាំ ២០០៥ ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

**៧- អណ្តើកហ្លួង** (*Batagur baska*) **ជានិមិត្តរូបសត្វនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា**



ឈ្មោះជាភាសាជាតិ "អណ្តើកសរសៃ ឬ អណ្តើកហ្លួង" ។ វាមានឈ្មោះវិទ្យាសាស្ត្រ " *Batagur baska* " និង ជាភាសាអង់គ្លេស គឺ " Royal Turtle"។ វាមានភ្នែកពណ៌ស និង ច្រមុះបះឡើង ស្នូករបស់វាមានប្រវែងរហូតដល់ ៦០ ស.ម មានផ្ទៃពណ៌ប្រផេះ ឬ ខ្មៅទាំងអស់ ។ ម្រាមជើងមុខធំមានស្បែកពាសជាប់គ្នាដូចបាតជើងទា មានក្រញ៉ាំតែបួន គឺ ខុសប្លែកពីអណ្តើកផ្សេងទៀត ដែលមានក្រញ៉ាំប្រាំ។ អណ្តើកនេះត្រូវហាមឃាត់មិនឱ្យធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយបានចុះក្នុងឧបសម្ព័ន្ធ I នៃអនុសញ្ញា CITES ។ ពិភពលោកបានចាត់ទុកអណ្តើកនេះជាប្រភេទសត្វ **កំពុងទទួលការគំរាមកំហែងជាសកល** (Globally Threaten) ដោយបានចុះក្នុងបញ្ជីសៀវភៅក្រហម IUCN ។ កាលពីបុរាណ អណ្តើកនេះ មានប្រវត្តិការពារដោយព្រះរាជក្រឹត្យ និង បានចាត់ទុកជាសម្បត្តិរបស់រាជវង្សនៅកម្ពុជាយើង ។ ពងអណ្តើកនេះ ជារឿយៗប្រមូលបានពីខែ មករា ដល់ខែ មីនា ដែលនៅពេលនោះគេយកទៅថ្វាយតែចំពោះរាជវង្សសោយប៉ុណ្ណោះ ដូចនេះទើបប្រជារាស្ត្រឱ្យឈ្មោះថា **អណ្តើកហ្លួង** រហូតដល់សព្វថ្ងៃនេះ ។ ក្រោយមកប្រជារាស្ត្រឱ្យតែចាប់បានអណ្តើកនេះ តែងតែយកមកតុបតែងលាបប្រេងម្សៅនិមន្តព្រះសង្ឃសូត្រធម៌បួងសួងសុំសេចក្តីសុខ ហើយដោះលែងទៅវិញ ។ វាចូលចិត្តរស់នៅតាមតំបន់ពាមសមុទ្រមានព្រែកតូចៗ ដែលមានព្រៃកោងកាង ឬ មានរុក្ខជាតិផ្សេងទៀតដុះតាមមាត់ទឹក ។ ជាប្រភេទសត្វស៊ីអាហារគ្រប់យ៉ាងមានស្លឹកឈើ ពន្លករុក្ខជាតិ ផ្លែកោងកាង និង សត្វតូចៗផ្សេងទៀត។ ក្នុងអំឡុងទសវត្សឆ្នាំ៨០ និង ៩០ គេជឿថាអណ្តើកនេះបានផុតពូជពីកម្ពុជាទៅហើយ ទើបតែនៅឆ្នាំ ១៩៩៥ បានរកឃើញនៅស្រុកស្រែអំបិល ខេត្តកោះកុង ហើយនៅឆ្នាំ ២០០២ កន្លងទៅនេះ នាយកដ្ឋានជលផលសហការជាមួយអង្គការ WCS ភ្ញាស់បាន ៣២កូន ហើយបានលែងទៅក្នុងធម្មជាតិវិញ ។ វាជាប្រភេទជិតផុតពូជ ដែលអង្គការអភិរក្សពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលនានាកំពុងមានចំណាប់អារម្មណ៍ ជួយផ្តល់ជំនួយការពារថែរក្សាប្រភេទសត្វនេះឱ្យខាងតែបាន និង ម្យ៉ាងទៀតគួបផ្សំនឹងទីជម្រកព្រៃកោងកាងដ៏ស្រស់ស្អាត វាជាប្រភពទាក់ទាញទេសចរណ៍មួយដ៏គួរឱ្យចាប់អារម្មណ៍ ។



៦/៧
~~~~~

# ឧបសម្ព័ន្ធ ទី៤

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៤ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥ ស្ដីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ៤- ត្រីគល់រាំង (*Catlocarpio siamensis*) ជាមច្ឆជាតិនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ " ត្រីកាហោ ឬ ត្រីក្បាលឡាន ឬត្រីគល់រាំង "។ វាមានឈ្មោះវិទ្យាសាស្ត្រ " Catlocarpio siamensis " និង ឈ្មោះជាភាសាអង់គ្លេស " Giant Mekong Barb"។ វាជាប្រភេទត្រីមានទំហំធំជាងគេនៅកម្ពុជា ។ វាអាចមានទម្ងន់ពី ១៥០-៣០០ គីឡូក្រាម និង ប្រវែងដងខ្លួនពី ២-៣ ម៉ែត្រ ។ ជាប្រភេទត្រីមានស្រកាធំៗគ្របដណ្ដប់លើផ្ទៃដងខ្លួនទាំងមូល លើកលែងតែផ្ទៃក្បាល និង ព្រុយប៉ុណ្ណោះ។ ពណ៌សម្បុរលើដងខ្លួនទាំងមូល មើលឃើញថាមានពីរពណ៌ដាច់ដោយឡែកពីគ្នា ស្រកាដែលនៅលើខ្សែឆ្អឹងចំហៀងខ្លួនមានពណ៌ក្រម៉ៅថ្លា ។ ដោយឡែក ស្រកាឋិតនៅក្រោមខ្សែឆ្អឹងចំហៀងខ្លួនមានពណ៌ប្រាក់ ។ ប្រភេទត្រីនេះ ត្រូវការពារដោយក្រឹត្យច្បាប់លេខ ៣៣ ក្រ.ច ស្ដីពីការគ្រប់គ្រងវិស័យជលផលក្នុងជំពូក ២ មាត្រា ១៨ ។ បច្ចុប្បន្ននេះនាយកដ្ឋានជលផលបានណែនាំ និង លើកទឹកចិត្តដល់ស្ថានីយ៍ភ្ញាស់ និង បង្កាត់ពូជត្រីនានា ឱ្យធ្វើការសិក្សាស្រាវជ្រាវភ្ញាស់ និង បង្កាត់ប្រភេទពូជត្រីនេះ ដើម្បីលែងចូលក្នុងដែនទឹកធម្មជាតិ និង ធ្វើវារីវប្បកម្ម ។ ចាប់តាំងពីឆ្នាំ ២០០០ មក នាយកដ្ឋានជលផលបានសហការជាមួយគម្រោងគ្រប់គ្រងនេសាទទឹកសាបកម្ពុជា បានធ្វើការលែងត្រីគល់រាំងដែលនេសាទបានដោយផ្ទាល់ ដោយដាក់សញ្ញាសម្គាល់ ដើម្បីតាមដានចរាចរ និង ការលូតលាស់របស់វា។ ត្រីគល់រាំងជាប្រភេទត្រីទឹកសាបមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ។ គេឃើញមានរស់នៅតាមដងទន្លេមេគង្គ ជាពិសេសសំបូរជាងគេនៅបឹងទន្លេសាប ។ រូបភាពប្រភេទត្រីនេះ ត្រូវបុព្វបុរសខ្មែរយើងឆ្លាក់ជារូបចម្លាក់ដាក់លើប្រាង្គប្រាសាទអង្គរវត្ត ។ គេនិយមយកស្រកាត្រីគល់រាំងមកធ្វើជាសីទាត់ក្នុងល្បែងប្រជាប្រិយខ្មែរយើង។ បើប្រៀបធៀបទៅនឹងប្រភេទត្រីក្នុងស្រុកផ្សេងទៀត ត្រីគល់រាំងមានមាឌធំជាងគេនៅក្នុងប្រទេសកម្ពុជា ហើយស្ទួតពុំដេញចាប់ប្រភេទត្រីផ្សេងទៀតជាអាហារឡើយ។ សាច់របស់វាមានរស់ជាតិឆ្ងាញ់ ប្រជាជននិយមចូលចិត្តបរិភោគ ។ បច្ចុប្បន្ននេះ យើងបាននិងកំពុងជំរុញដល់ស្ថានីយ៍ភ្ញាស់បង្កាត់នានា ឱ្យព្យាយាមស្រាវជ្រាវភ្ញាស់ផលិតពូជត្រីនេះ ដើម្បីផ្សព្វផ្សាយឱ្យប្រជាកសិករយកទៅចិញ្ចឹម ព្រោះវាងាយស៊ីចំណីធម្មជាតិឆាប់ធំ និង អាចរក្សាពូជរបស់វាបាន ។ ទន្ទឹមនឹងនេះដែរ យើងបានបង្កើតតំបន់ការពារអន្លង់ត្រីជាច្រើននៅតាមទន្លេមេគង្គ ដើម្បីអភិរក្សពូជត្រីដ៏ជិតផុតពូជនេះ ។ វាជាប្រភេទត្រីមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ សម្រាប់ការផ្សព្វផ្សាយឱ្យប្រជាកសិករចិញ្ចឹម ព្រោះវាងាយស៊ីចំណីធម្មជាតិ និង ឆាប់ធំ និង ជាប្រភេទជិតផុតពូជ ដែលអង្គការអភិរក្សពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលនានា កំពុងមានចំណាប់អារម្មណ៍ជួយផ្ដល់ជំនួយការពារថែរក្សាប្រភេទត្រីនេះឱ្យខាងតែបាន ។
~~~~~

# ឧបសម្ព័ន្ធ ទី៥

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥
## ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ៥- ដើមត្នោត *(Borassus flabellifer)* ជារុក្ខជាតិនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "ត្នោត" ។ វាមានឈ្មោះវិទ្យាសាស្ត្រ " ***Borassus flabellifer*** " និង ជាភាសាអង់គ្លេស គឺ " **Sugar Palm** " ។ ត្នោតជាប្រភេទរុក្ខជាតិស្ថិតក្នុងតាលព្រឹក្សខ្ពស់ មានដើមទោល គល់ធំ ដុះត្រង់ឡើងលើ កម្ពស់ពី ១០-២៥ ម ឬសវាមានលក្ខណៈជាឬសយោង និង គ្មានឬសកែវ ។ តួដើមត្នោតមានភាពគគ្រើមពណ៌ក្រម៉ៅ អង្កត់ផ្ចិតពី ២០-៦០ ស.ម ដោយប្រែប្រួលទៅតាមគុណភាពដី ។ កន្សោមស្លឹកមានរាងដូចផ្ចិត ប្រមូលផ្តុំគ្នានៅផ្នែកចុងកំពូលនៃដើម ។ ធាងត្នោតរលោងក្រាស់មានពណ៌លឿងបៃតងពេលនៅខ្ចី និង លឿងត្នោតពេលមានអាយុចាស់ ព្រមទាំងមានបន្លានៅតែមទាំងសងខាងសណ្ឋានដូចជាធ្មេញរណារ ។ ត្នោតញី និង ឈ្មោលមានលក្ខណៈខុសប្លែកគ្នាតាមការសម្គាល់លើផ្ការបស់វា ។ ផ្កាត្នោតឈ្មោលមានរាងមូលទ្រវែង ទំហំពី ២-៤ ស.ម ប្រវែងពី ៣០-៥០ ស.ម ។ រីឯផ្កាត្នោតញីមានសណ្ឋានជាពកមូលៗប្រវែងពី ៥០-៧០ ស.ម ដែលអាចផ្តល់ផ្លែបានចំនួនពី ២០-៥០គ្រាប់ ។ ផ្លែត្នោតមានរាងមូលពណ៌ត្នោតក្រម៉ៅនៅភាគខាងក្រោម និង ពណ៌បៃតងនៅភាគខាងលើនៃផ្លែ ហើយប្រែពណ៌ទៅជាលឿងទុំក្រម៉ៅពេលវាចាស់-ទុំ ។ ផ្លែត្នោតមានអង្កត់ផ្ចិត ប្រមាណពី ១៣-២០ ស.ម ដែលប្រែប្រួលទៅតាមគុណភាពដី ការកៀបយកទឹក និង អាយុកាលរបស់ដើម ។ ត្នោតជារុក្ខជាតិប្រជាប្រិយ៍តំណាងឱ្យសង្គមខ្មែរ ដែលមានវត្តមាន និង ផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដល់ប្រជាជាតិខ្មែរតាំងពីសម័យកំណកំណើតនគរខ្មែរ និង ជាអត្តសញ្ញាណដែលប្រជាជនខ្មែរសម្គាល់នូវទេសភាពទឹកដីរបស់ខ្លួន តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន ស្របនិងពាក្យស្លោកថា " **ដើមត្នោតជាជម្រកផ្ទះខ្មែរ** " ។ កាលពីឆ្នាំ ២០០៣ កន្លងទៅនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ មានវិធានការទប់ស្កាត់កុំមានការបំផ្លាញទ្រព្យធម្មជាតិដូចជា: ព្រៃឈើ និង ដើមត្នោតជាដើម ដែលបន្ទាប់មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានចេញនូវសារាចរណែនាំលេខ ៤៨១ សរណន.កសក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីវិធានការទប់ស្កាត់ការជីកជញ្ជូន និង ធ្វើអាជីវកម្មដើមត្នោត ។ ក្នុងសង្គមខ្មែរ ដើមត្នោតមានសារៈសំខាន់ច្រើនយ៉ាងណាស់ដូចជា: ឬសត្នោត និង ផ្កាត្នោតឈ្មោលជាឱសថបុរាណសំរាប់កែរោគគ្រុនចាញ់ កាមរោគ ឬ រោគស្ពឹកចុងដៃចុងជើង ។ ដើមត្នោតអាចយកមកប្រើប្រាស់នៅក្នុងសំណង់លំនៅស្ថាន ក្រោលសត្វ ទូក ឬ សំណង់ផ្សេងទៀត ។ បច្ចុប្បន្នដើមត្នោតបានកែច្នៃជាផលិតផលសិប្បកម្មដ៏មានតម្លៃក្នុងទីផ្សារ ។ ស្លឹកសម្រាប់ប្រក់ និង ធ្វើជញ្ជាំងផ្ទះ ត្បាញកន្ទេល មួក ស្មុក និង ពេលខ្លះអាចប្រើប្រាស់ស្លឹកត្នោតសម្រាប់ចារ ឬ សរសេរជំនួសស្លឹករឹត ទ្រាំង បានទៀតផង ។ ផ្លែត្នោត និង ទឹកត្នោតមានឱជារសឈ្ងុយឆ្ងាញ់ពិសារជាទីពេញនិយមនៃសង្គមខ្មែរ ។ ការផលិតស្ករត្នោតដោយរំងាស់ពីទឹកត្នោត គឺជាប្រពៃណីរបស់ប្រជារាស្ត្រខ្មែរតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ។
~~~~~

# ឧបសម្ព័ន្ធ ទី៦

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១៤៩ ចុះថ្ងៃទី...២១... ខែ...មីនា... ឆ្នាំ ២០០៥ ស្តីពី ការកំណត់ប្រភេទសត្វ និង រុក្ខជាតិ ជានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា

~~~~~

### ៦- ផ្ការំដួល *(Mitrella mesnyi )* ជាផ្កានិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "រំដួល "។ វាមានឈ្មោះវិទ្យាសាស្ត្រ " **Mitrella mesnyi**" ។ រំដួលជាប្រភេទរុក្ខជាតិមានកម្ពស់ពី ៨-១២ម និង មានអង្កត់ផ្ចិតពី ២០-៣០ស.ម ។ ដើមមានសំបកពណ៌ត្នោត-លឿង ស្លឹកជាប្រភេទស្លឹកទោលដុះឆ្លាស់ គ្មានខ្នាយស្លាប ទម្រង់បន្ទះស្លឹករាងទ្រវែងមានទំហំ ២-៤ x ៦-១០ ស.ម ។ ផ្ការំដួលមានពណ៌លឿង-ស មានក្លិនក្រអូបផ្សាយបានឆ្ងាយ ចោលក្លិននៅពេលរសៀល និង ពេលព្រលប់ ។ ផ្លែជាចង្កោម ពេលទុំមានពណ៌ក្រហមក្រម៉ៅអាចបរិភោគបាន ។ រំដួលមានដុះលូតលាស់ដោយធម្មជាតិស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ហើយត្រូវបានប្រជាជនយើងនិមយយកមកដាំលំអតាមគេហដ្ឋាន និងសួនសាធារណៈ។ ដោយផ្ការំដួលមានក្លិនក្រអូបរបៀបនេះ ខ្មែរយើងពីបុរាណកាលនិយមប្រើប្រាស់វាជាគ្រឿងផ្សំផលិតជាក្រមួនលាបមាត់របស់នារី ។ ដើមរំដួលក៏អាចកែច្នៃប្រើប្រាស់ជាគ្រឿងសំណង់បន្ទាប់បន្សំ និង ប្រើជាអុសសំរាប់ដុត ។ នៅរដូវផ្លែរំដួលទុំ ប្រជាជនដែលរស់នៅក្បែរព្រៃតែងតែបេះផ្លែរំដួលយកមកលក់ដោះស្រាយជីវភាព ។ ដោយសារផ្ការំដួលមានក្លិនដ៏ក្រអូបជាទីទាក់ទាញអារម្មណ៍របស់មហាជនទូទៅ ហេតុនេះបានជានៅក្នុងសង្គមខ្មែរ គេច្រើនប្រដូចនារីខ្មែរទៅនឹងផ្ការំដួលរហូតដល់មានកវីនិពន្ធខ្មែរខ្លះបានបន្សល់ទុកនូវបទចម្រៀងមួយចំនួនដូចជា: **រំដួលក្រចេះ** និង **រំដួលពោធិសាត់** ជាដើម ។

### ៧- ចេកពងមាន់ *Banana (Musa aromatica)* ជាផ្លែឈើនិមិត្តរូបនៃព្រះរាជាណាចក្រកម្ពុជា



ឈ្មោះជាភាសាជាតិ "ចេកពងមាន់ "។ វាមានឈ្មោះវិទ្យាសាស្ត្រ "**Musa aromatica**" និង ជាភាសាអង់គ្លេស គឺ " **Chicken Egg Banana**" ។ ចេកត្រូវគេនិយមបរិភោគ និង ប្រើប្រាស់ជាទូទៅដោយប្រជាជនកម្ពុជាគ្រប់ជាន់ថ្នាក់ ។ គេអាចបរិភោគផ្លែចេកទុំ ឬ កែច្នៃជាដំណាប់ ចេកបន្ទះ ចេកឆាប ជាដើម ។ ក្រៅពីនេះ ចេកប្រជាជនកម្ពុជានិយមប្រើជាសំណែន ឬ ជំនូនគ្រប់ពិធីផ្សេងៗ ដែលសូម្បីតែសម្រាប់ថ្វាយគោរពបូជាទេវតារាល់ថ្ងៃសីលផងដែរ ។ ក្នុងពាក្យស្លោក " ពេលឈឺយកដីទៅបន់ ពេលជាសះស្រន់ចេកពងមាន់ក៏ស្តាយ " នោះបញ្ជាក់ថា ចេកត្រូវប្រើប្រាស់ជាទូទៅ ព្រោះមានតម្លៃថោក ហើយផលិតផលនេះមានពោរពេញគ្រប់ទិសទី ។ ចេកពងមាន់ភាគច្រើនត្រូវគេដាំនៅតាមដីសណ្តទន្លេមេគង្គ ជាពិសេសនៅតាមតំបន់កោះដុះថ្មី ។ ចេកគេដាំនៅកម្ពុជា ជាយូរលង់ណាស់មកហើយ ថ្វីត្បិតតែជាដំណាំដែលមានប្រភពពីឥណ្ឌាក៏ដោយ ។ តួយ៉ាងរឿងព្រេងបុរាណខ្មែរ " ចៅស្រទបចេក " ជាភស្តុតាងស្រាប់ ។ ក្រៅពីបានដាំយកផ្លែ ដើម្បីជាប្រភពចំណូលប្រចាំគ្រួសាររបស់កសិករនោះដំណាំចេកជាដំណាំប្រើបានច្រើនមុខទៀត ដូចជា: គល់របស់វាជាប្រភពជាតិម្សៅ ( អាមីដុង) ពិសេសក្នុងពេលជួបគ្រោះទុរ្ភិក្សម្តងមួយកាល ដើមវាអាចហាន់ជាចំណីជ្រូក គោ ក្របី ។ល។ ធ្វើជាខ្សែចំណងផ្សេងៗ ធ្វើជាបាយសីក្នុងពិធីសែនព្រេននានា ស្លឹកប្រើជាសម្ភារៈវេចខ្ចប់នំចំណី និង ត្រយូងប្រើជាបន្លែស្រស់ ឬ ស្ល ។
~~~~~

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៥១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌ ឧត្តមសេនីយ៍ទោ ចាន់ វាសនា អត្តលេខ ០២៤៦ ពីក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ នៃ ក្រសួងមហាផ្ទៃ មកបំរើការងារក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ នៃក្រសួងការពារជាតិ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធរល.០៥០៣.១៥៧*

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥*

លេខ: ៣៣៧ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០០៥
[illegible] ទីស្តីការគណៈរដ្ឋមន្ត្រី [illegible] រាជរដ្ឋាភិបាល
**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងសុខាភិបាល ដូចខាងក្រោម :

១. ឯកឧត្តម ឆេព លង់ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល

